



ដោយប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីពីរ ក្នុងគណៈប្រធានទីមួយ

# ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មនៅរស់

នៅក្នុងរដូវកាលនេះជួយយើងឲ្យចងចាំអំពីការលះបង់របស់ព្រះអង្គសង្គ្រោះ និងរស់ឡើងវិញពីផ្នូររបស់ទ្រង់ ។

មានពេលមួយខ្ញុំបានឈរជាមួយភរិយារបស់ខ្ញុំ នៅខាងក្រៅផ្នូរមួយនៅក្នុងទីក្រុងយេរូសាឡិម ។ នៅខាងក្នុងយើងបានឃើញកៅអីថ្មមួយនៅទល់នឹងជញ្ជាំង ។

ប៉ុន្តែមានរូបភាពមួយទៀតបានចូលមកក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំបានគិតអំពីម៉ារា នៅក្នុងផ្នូរទទេនោះ ។ នាងបានយំ ពីព្រោះព្រះអង្គសង្គ្រោះបានសុគត ។ នាងមិនបានដឹងថាព្រះកាយរបស់ទ្រង់នៅទីណានោះទេ ។

បន្ទាប់មក « នាងបែរខ្លួនទៅក្រោយ ហើយឃើញព្រះយេស៊ូវទ្រង់ឈរ តែមិនដឹងជាព្រះយេស៊ូវទេ » ( យ៉ូហាន ២០:១៤ ) ។ ម៉ារី បានគិតថាទ្រង់គឺជាអ្នកថែសួន ។

« ព្រះយេស៊ូវ បានមានព្រះបន្ទូលទៅកាន់នាងថា ម៉ារា » ( យ៉ូហាន ២០:១៦ ) ។ ឥឡូវ ម៉ារា បានស្គាល់ទ្រង់ហើយ ។ នាងបានដឹងថាទ្រង់បានមានព្រះជន្មរស់ឡើងវិញហើយ ។

ដោយសារព្រះយេស៊ូវគ្រីស្ទបានយកឈ្នះនៅលើសេចក្តីស្លាប់ នោះបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌ទាំងអស់នឹងត្រូវបានរស់ឡើងវិញ នៅក្នុងរូបកាយមួយដែលនឹងមិនចេះស្លាប់ឡើយ ។

ខ្ញុំអរព្រះគុណព្រះវរបិតាសួគ៌ចំពោះអំណោយនៃព្រះរាជបុត្រាដ៏ស្ងួនភ្ញារបស់ទ្រង់ ។ ខ្ញុំមានអំណរគុណដែលដឹងថាទ្រង់បានធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់យើង ហើយបានមានព្រះជន្មរស់ឡើងវិញនៅក្នុងការរស់ឡើងវិញ ។ « ខ្ញុំថ្លែងទីបន្ទាល់ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ ហើយជាគំរូដ៏ឥតខ្ចោះរបស់យើង ។

ដកស្រង់ចេញពី « His Spirit to Be with You » *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៨៦-៨៩ និង « ទ្រង់មានព្រះជន្មរស់ឡើងវិញ » *លីអាហូណា* ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៤-៥ ។









## រង្វង់កង់ដំណើររឿងនៃបុណ្យអ៊ីស្ទើរ

កាត់រង្វង់ចេញ ហើយដាក់រង្វង់ទីមួយនៅលើរង្វង់មួយទៀត ។ ចោះរន្ធនៅចំកណ្តាល ហើយភ្ជាប់រង្វង់ទាំងពីរឲ្យជាប់ ដោយប្រើដែកខ្ទាស់ ឬដែកកីប ។ បន្ទាប់មកបង្វិលរង្វង់ខាងលើ ដើម្បីប្រាប់អំពីដំណើររឿងនៃបុណ្យអ៊ីស្ទើរ ។